# ឱកាសដែលមានតែម្ដងនៅក្នុងជីវិត

*ដោយអែលឌើរ ដបុលយូ គ្រីស្តូហ្វើរ វ៉ែតឌែល*
*នៃពួកចិតសិប*

ព្រឹត្តការណ៍មួយដ៏សំខាន់នៃជីវិតរបស់អ្នកផ្សាយសាសនាម្នាក់ គឺការសម្ភាសន៍ « ចាកចេញ» ឬការសម្ភាសន៍ចុងក្រោយជាមួយនឹងប្រធានបេសកកម្មរបស់ខ្លួន ។ ក្នុងអំឡុងពេលនៃការសម្ភាសន៍នឹងមានការពិភាក្សាពីអ្វីដែលជាបទពិសោធន៍តែមួយគត់ដែលគួរឲ្យចងចាំ និងជាមេរៀនដ៏សំខាន់ ដែលបានទទួលក្នុងរយៈពេល 18 ទៅ 24 ខែ ។

មេរៀន និងបទពិសោធន៍ទាំងនេះ ប្រហែលជាវាជារឿងធម្មតាចំពោះការបម្រើបេសកកម្ម បេសកកម្មនីមួយៗ គឺសំខាន់ មានឧបសគ្គ និងឱកាសដែលនឹងតម្រង់ និងសាកល្បងយើង ស្របទៅតាមតម្រូវការ និងបុគ្គលិកលក្ខណៈជាក់លាក់នានារបស់យើង ។

ជាយូរយារមកហើយ ពីមុនចាកចេញពីផ្ទះលើផែនដីរបស់យើងដើម្បីចេញបម្រើបេសកកម្មពេញម៉ោង យើងបានចាកចេញពីព្រះមាតាបិតាសួគ៌របស់យើង ដើម្បីបំពេញបេសកកម្មនៅលើផែនដីរបស់យើង ។ យើងមានព្រះបិតាដែលគង់នៅស្ថានសួគ៌ ដែលស្គាល់យើង---ជ្រាបពីកម្លាំង និងភាពទន់ខ្សោយ សមត្ថភាព និងសក្តានុពលរបស់យើង ។ ទ្រង់ជ្រាបយ៉ាងច្បាស់ថាប្រធានបេសកកម្ម ដៃគូ សមាជិក និងអ្នករៀនបែបណាដែលយើងត្រូវការដើម្បីក្លាយជាអ្នកផ្សាយសាសនា ស្វាមី និងឪពុក និងអ្នកកាន់បព្វជិតភាពដែលយើងអាចមានលទ្ធភាពប្រែក្លាយ។

ពួកព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈចាត់តាំងពួកអ្នកផ្សាយសាសនាក្រោមការដឹកនាំ និងឥទ្ធិពលព្រះវិញ្ញាណបរិសុទ្ធ ។ ប្រធានបេសកកម្មដ៏ប្រកបដោយការបំផុស ដឹកនាំការផ្លាស់ប្តូរជារៀងរាល់ប្រាំមួយសប្តាហ៍ម្តង ហើយដឹងយ៉ាងរហ័សថា ព្រះអម្ចាស់ដឹងពីទីកន្លែងជាក់លាក់ដែលទ្រង់សព្វព្រះទ័យឲ្យអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗទៅបម្រើ ។

ពីរបីឆ្នាំមុន អែលឌើរ ចាវៀ មីស៊ីហ្គូ មកពីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ បានបម្រើបេសកកម្មពេញម៉ោងក្នុងរដ្ឋអារីហ្សូណា ។ នៅពេលនោះ ការហៅគាត់ឲ្យបម្រើនៅសហរដ្ឋអាមេរិក បានលេចឡើងជារឿងមួយដែលខុសពីធម្មតា ពីព្រោះយុវជនភាគច្រើនក្នុងប្រទេសអេស្ប៉ាញ ត្រូវបានហៅឲ្យបម្រើនៅក្នុងប្រទេសកំណើតរបស់ខ្លួន ។

នៅចុងបញ្ចប់នៃការប្រជុំស្តេកពិសេសមួយ ជាការប្រជុំដែលគាត់ និងដៃគូគាត់ត្រូវបានអញ្ជើញឲ្យចូលរួម ស្រាប់តែមានសមាជិកមិនសូវសកម្មម្នាក់ដែលត្រូវមិត្តភក្តិបាននាំមក បានដើរមករកអែលឌើរ មីស៊ីហ្គូ ។ នេះជាលើកដំបូងក្នុងអំឡុងពេលដ៏ច្រើនឆ្នាំដែលបុរសនេះបានចូលមកក្នុងសាលាប្រជុំ ។ បុរសនោះបានសួរ អែលឌើរ មីស៊ីហ្គូ ប្រសិនបើគាត់ស្គាល់ ចូស មីស៊ីហ្គូនៅក្រុងម៉ាឌ្រីដ ។ ពេលនោះអែលឌើរ មីស៊ីហ្គូ បានឆ្លើយថាឪពុកគាត់ឈ្មោះ ចូស មីស៊ីហ្គូ បុរសនោះបានសួរពីរបីសំនួរទៀតដោយរំភើបដើម្បីប្រាកដថាជា ចូស មីស៊ីហ្គូ ម្នាក់នោះមែន។ នៅពេលដឹងថាពួកគេកំពុងតែនិយាយអំពីមនុស្សតែមួយ នោះសមាជិកមិនសូវសកម្មរូបនេះ បានចាប់ផ្តើមយំ ។ « ឪពុកអ្នក គឺជាមនុស្សតែម្នាក់គត់ដែលខ្ញុំបានធ្វើបុណ្យជ្រមុជទឹកឲ្យក្នុងអំឡុងពេលបេសកកម្មខ្ញុំ » គាត់បានពន្យល់ និងរ៉ាយរ៉ាប់ពីបេសកកម្មរបស់គាត់ថា ជាការបរាជ័យមួយនៅក្នុងគំនិតរបស់គាត់ ។ គាត់បានឃើញថាច្រើនឆ្នាំនៃការមិនសូវសកម្មរបស់គាត់ប្រៀបដូចជាអារម្មណ៍នៃការខ្វះខាត និងកង្វល់ ដោយជឿថា គាត់បានធ្វើឲ្យព្រះអម្ចាស់អស់សង្ឃឹម ។

ក្រោយមក អែលឌើរ មីស៊ីហ្គូ បានពិពណ៌នានូវអ្វីដែលអ្នកផ្សាយសាសនាម្នាក់ « ស្មានថាជាការបរាជ័យ » មានអត្ថន័យចំពោះក្រុមគ្រួសារគាត់ ។ គាត់បានប្រាប់បុរសនោះថា ប៉ារបស់គាត់ បានទទួលបុណ្យជ្រមុជទឹកកាលពីមជ្ឈឹមវ័យវ័យក្មេង បានរៀបការក្នុងព្រះវិហារបរិសុទ្ធ ដែលអែលឌើរ មីស៊ីហ្គូ ជាកូនទីបួនក្នុងចំណោមកូនទាំងប្រាំមួយនាក់ ដែលមានកូនប្រុសទាំងបី និងកូនស្រីម្នាក់ បានបម្រើបេសកកម្មពេញម៉ោង កូនទាំងអស់សកម្មក្នុងសាសនាចក្រ ហើយថាកូនទាំងអស់ដែលរៀបការហើយ បានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ។

អ្នកត្រឡប់ពីបេសកកម្មដែលមិនសូវសកម្មរូបនោះ បានយំខ្សឹបខ្សួល ។ តាមរយៈការខិតខំរបស់គាត់ ឥឡូវគាត់ដឹងថា មានមនុស្សជាច្រើនបានទទួលពរជ័យ ហើយព្រះអម្ចាស់បានបញ្ជូន អែលឌើរមកពីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ ពីទីដ៏សែនឆ្ងាយដើម្បីចូលរួមការប្រជុំពិសេសនោះក្នុងរដ្ឋអារីហ្សូណា ដើម្បីឲ្យគាត់ដឹងថា គាត់មិនបានបរាជ័យនោះទេ ។ ព្រះអម្ចាស់ជ្រាបពីទីដែលទ្រង់មានព្រះទ័យឲ្យអ្នកផ្សាយសាសនាម្នាក់ៗដើម្បីបម្រើ ។

តាមវិធីណាក៏ដោយព្រះអម្ចាស់អាចជ្រើសរើសដើម្បីប្រទានពរដល់យើងក្នុងអំឡុងពេលបេសកកម្ម ពរជ័យនានានៃការបម្រើបេសកកម្មពុំបានបញ្ចប់ នៅពេលយើងត្រូវបានដោះលែងដោយប្រធានស្តេកយើងនោះទេ ។ បេសកកម្មរបស់អ្នក គឺជាការបំពាក់បំប៉នអស់មួយជីវិត ។ បទពិសោធន៍ មេរៀននានា និងទីបន្ទាល់ដែលបានទទួលតាមរយៈការបម្រើដ៏ស្មោះត្រង់ គឺជាមធ្យោបាយដើម្បីផ្តល់នូវមូលដ្ឋានគ្រឹះនៃដំណឹងល្អដែលនឹងស្ថិតនៅរហូតដល់អមតភាព និងអស់កល្បជានិច្ច ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឲ្យពរជ័យទាំងឡាយនៅតែបន្តមានបន្ទាប់ពីបេសកកម្ម នោះមាននូវលក្ខខណ្ឌមួយចំនួនដែលត្រូវធ្វើ ។ « ត្បិតអស់អ្នកណាដែលនឹងបានព្រះពរពីព្រះហស្តរបស់យើង នោះនឹងនៅជាប់នឹងក្រឹត្យវិន័យដែលបានតាំងសម្រាប់ព្រះពរនោះ » ( គ. និង ស. 132:5 ) ។

គោលការណ៍នេះត្រូវបានបង្រៀននៅក្នុងដំណើររឿងមួយនៃព្រះគម្ពីរនិក្ខមនំ ។ ក្រោយពីបានទទួលអំណាចពីព្រះអម្ចាស់ ម៉ូសេបានត្រឡប់ទៅអេស៊ីព្ទវិញដើម្បីដឹកនាំកូនចៅអ៊ីស្រាអែលចេញពីសេវកភាព ។ សេចក្តីវេទនាមួយហើយមួយទៀត ធ្វើឲ្យបរាជ័យដល់ការការពារសេរីភាពរបស់ពួកគេ ហើយដឹកនាំទៅរកសេចក្តីវេទនាទី 10 និងចុងក្រោយថា ៖ « ត្បិតនៅយប់នោះអញនឹងដើរកាត់ស្រុកអេស៊ីព្ទ ហើយវាយអស់ទាំងកូនច្បងនៅក្នុងស្រុក » ( និក្ខមនំ 12:12 ) ។

ដើម្បីការពារប្រឆាំងនឹង « មេបំផ្លាញ » ( ខទី 23 ) ព្រះអម្ចាស់បានណែនាំរាស្ត្រទ្រង់ឲ្យថ្វាយយញ្ញបូជាចៀម « ឥតខ្ចោះ » ( ខទី 5 ) ហើយត្រូវប្រមូលឈាមពីយញ្ញបូជា ។ ក្រោយមកពួកគេត្រូវ « យកឈាម » ដាក់នៅមាត់ច្រកទ្វាផ្ទះនីមួយៗ---« ទាំងសង្ខាង ហើយលើធ្នឹម ( ខទី 7 )---ដោយសេចក្តីនេះ ៖ « កាលណាយើងឃើញឈាម នោះយើងនឹងរំលងផុតពីអ្នករាល់គ្នាទៅ ហើយនឹងគ្មានសេចក្តីវេទនាណាបំផ្លាញអ្នករាល់គ្នា » ( ខទី 13 ) ។

« កូនចៅអ៊ីស្រាអែលនាំគ្នាទៅធ្វើតាមសេចក្តីដែលព្រះយេហូវ៉ាបានបង្គាប់ » ( ខទី 28 ) ។ ពួកគេបានប្រមូលឈាម ហើយបានដាក់វានៅផ្ទះរបស់គេ ។ « រីឯនៅកណ្តាលអធ្រាតយប់នោះ ព្រះយេហូវ៉ាទ្រង់ក៏បានវាយអស់ទាំងកូនច្បងនៅស្រុកអេស៊ីព្ទ » ( ខទី 29 ) ។ ម៉ូសេនិងប្រជាជនគាត់ ត្រូវបានការពារស្របតាមការសន្យារបស់ព្រះយេហូវ៉ា ។ ឈាមដែលបានប្រើដោយសាសន៍អ៊ីស្រាអែល ជានិមិត្តសញ្ញានៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះនាពេលអនាគត គឺជាផលមួយមកពីយញ្ញបូជាដែលពួកគេបានថ្វាយ ។ ទោះជាយ៉ាងណាក៏ដោយ យញ្ញបូជា និងឈាមនឹងពុំបានគ្រប់គ្រាន់ដើម្បីទទួលពរជ័យដែលបានសន្យាឡើយ ។ បើគ្មានការដាក់ឈាមនៅលើធ្នឹមទ្វាទេ នោះយញ្ញបូជានឹងឥតប្រយោជន៍ ។

ប្រធានម៉នសុន បានប្រង្រៀនថា ៖ « កិច្ចការផ្សាយសាសនាគឺមានការលំបាក ។ វាដាក់បន្ទុកលើកម្លាំងមនុស្សម្នាក់ វាដាក់បន្ទុកលើសមត្ថភាពមនុស្សម្នាក់ វាទាមទារឲ្យមានកិច្ចខិតខំដ៏ខ្លាំងបំផុតពីមនុស្សម្នាក់ ។... គ្មានការបម្រើណាដែលតម្រូវឲ្យធ្វើច្រើនម៉ោង ឬមានការលះបង់ ឬមានការអធិស្ឋានដ៏ក្លៀវក្លា និងការលះបង់លើសពីនេះឡើយ » («That All May Hear » *Ensign* ខែ ឧសភា ឆ្នាំ 1995 ទំព័រ 49) ។

ជាលទ្ធផលនៃ «ពលិកម្ម» យើងត្រឡប់ពីបេសកកម្មរបស់យើងដោយមាននូវអំណោយផ្ទាល់ខ្លួន ។ អំណោយនៃសេចក្តីជំនឿ ។ អំណោយនៃទីបន្ទាល់ ។ អំណោយនៃការយល់ដឹងពីតួនាទីរបស់ព្រះវិញ្ញាណ ។ អំណោយនៃការសិក្សាដំណឹងល្អជារៀងរាល់ថ្ងៃ ។ អំណោយដែលបានបម្រើដល់ព្រះអង្គសង្គ្រោះ។ អំណោយដែលបានខ្ទប់ដោយប្រុងប្រយ័ត្ននៅក្នុងព្រះគម្ពីរដ៏ខ្ទក់ខ្ទី សៀវភៅប្រកាសដំណឹងល្អរបស់យើងដែលដាច់រយ៉េរយ៉ៃ ទិន្នានុប្បវត្តបេសកកម្ម និងដួងចិត្តដែលពោរពេញដោយការដឹងគុណ ។ ទោះជាយ៉ាងណាក៏ដោយ ដូចជាកូនចៅអ៊ីស្រាអែលដែរ ការបន្តទទួលបានពរជ័យដែលទាក់ទងទៅនឹងការបម្រើបេសកកម្មតម្រូវឲ្យមានការអនុវត្តន៍ក្រោយពីធ្វើការលះបង់ ។

ពីរបីឆ្នាំមុន ពេលស៊ិស្ទើរ រ៉ាខេល និងខ្ញុំបានដឹកនាំបេសកកម្មបាសេឡូណាអេស្ប៉ាញ ខ្ញុំនឹងដាក់ការចាត់តាំងមួយចុងក្រោយឲ្យអ្នកផ្សាយសាសនាម្នាក់ៗ ក្នុងអំឡុងពេលការសម្ភាសន៍ចុងក្រោយពួកគេ ។ នៅពេលពួកគេត្រឡប់ទៅផ្ទះពួកគេវិញ សុំឲ្យចំណាយពេលពិចារណា ភ្លាមៗពីមេរៀន និងអំណោយនានាដែលបានផ្តល់ឲ្យពួកគេដោយព្រះ វរបិតាដែលពោរពេញដោយសេចក្តីសប្បុរសដែលគង់នៅឯស្ថានសួគ៌ ។ ពួកគេត្រូវបានសុំឲ្យធ្វើបញ្ជីអធិស្ឋានដោយប្រុងប្រយ័ត្ន និងពិចារណាពីវិធីដ៏ល្អបំផុតដើម្បីអនុវត្តមេរៀនទាំងនោះនៅក្នុងជីវិតបន្ទាប់ពីបេសកកម្ម ៖ មេរៀនទាំងឡាយដែលជះឥទ្ធិពលលើគ្រប់វិស័យនៃជីវិតពួកគេមាន---ការអប់រំ ជម្រើសអាជីព អាពាហ៍ពិពាហ៍ និងកូនចៅ ការបម្រើនៅក្នុងសាសនាចក្រនាពេលអនាគត---សំខាន់បំផុត គឺមនុស្សដែលពួកគេនឹងបន្តប្រែក្លាយ និងការអភិវឌ្ឍន៍ជាបន្តបន្ទាប់របស់ពួកគេក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។

វាមិនយឺតពេលពេកទេ សម្រាប់អ្នកត្រឡប់ពីបេសកកម្មម្នាក់ៗដើម្បីពិចារណាមេរៀនទាំងឡាយ ដែលបានទទួលតាមរយៈការបម្រើដ៏ស្មោះត្រង់របស់ខ្លួន និងអនុវត្តវាកាន់តែយកចិត្តទុកដាក់ថែមទៀតនៅក្នុងជីវិតគាត់នោះ ។ កាលណាយើងធ្វើដូច្នោះ យើងនឹងទទួលឥទ្ធិពលពីព្រះវិញ្ញាណកាន់តែខ្លាំងថែមទៀតនៅក្នុងជីវិតយើង ក្រុមគ្រួសារយើងនឹងបានពង្រឹង ហើយយើងនឹងខិតកាន់តែក្លាយដូចជាព្រះអង្គសង្គ្រោះ និងព្រះវរបិតាដែលគង់នៅស្ថាន

សួគ៌យើង ។ នៅក្នុងសន្និសីទទូទៅមុននេះ  អែលឌើរ អិល ថម ភែរី បានផ្ដល់នូវការអញ្ជើញនេះថា ៖ « ខ្ញុំអញ្ជើញអ្នកដែលជាពួកអ្នកត្រឡប់ពីបេសកកម្មទាំងឡាយឲ្យពុះពារខ្លួនអ្នកសារជាថ្មី មើលនៅក្នុងខ្លួនអ្នកម្ដងទៀតនូវបំណង និងវិញ្ញាណនៃការបម្រើបេសក-កម្ម ។

ខ្ញុំអញ្ជើញឲ្យអ្នកមើលដូចជា ក្លាយដូចជា និងប្រព្រឹត្តដូចជាអ្នកបម្រើរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌យើង ។... ខ្ញុំចង់សន្យាដល់អ្នកថា មាននូវពរជ័យដ៏មហិមារៀបចំសម្រាប់អ្នក ប្រសិនបើអ្នកបន្ដទៅមុខដោយអំណាចដែលអ្នកធ្លាប់មានក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងមួយរូប » ( «The Returned Missionary » *Liahona* ខែ មករា ឆ្នាំ 2002 ទំព័រ 88, 89 *Ensign* ខែ វិច្ឆិកា ឆ្នាំ 2001 ទំព័រ 77) ។

ឥឡូវនេះ ចំពោះយុវជនដែលពុំទាន់បានបម្រើបេសកកម្មពេញម៉ោងនៅឡើយ ខ្ញុំសូមចែកចាយការប្រឹក្សារបស់ប្រធានម៉នសុន កាលពីខែតុលាឆ្នាំមុនថា ៖ « ខ្ញុំសុំរំឭកនូវអ្វីដែលពួកព្យាការីបានបង្រៀនជាយូរមកហើយ---ថាគ្រប់យុវជនទាំងអស់ដែលមានលទ្ធភាព និងស័ក្ដិសមគួរតែរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ។ ការបម្រើបេសកកម្ម គឺជាកាតព្វកិច្ចបព្វជិតភាព---ជាកាតព្វកិច្ចដែលព្រះអម្ចាស់បានរំពឹងដល់យើង ដែលបានប្រទានពរឲ្យជាច្រើន » ( «As We Meet Together Again » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 5--6) ។

ដូចជាពួកអ្នកផ្សព្វផ្សាយសាសនាពីអតីត និងបច្ចុប្បន្ន ព្រះអម្ចាស់ស្គាល់អ្នក ហើយនិងមានបទពិសោធន៍បេសកកម្មមួយ បានរៀបចំឲ្យអ្នក ។ ទ្រង់ស្គាល់ប្រធានបេសកកម្មអ្នក និងភរិយាដ៏ល្អរបស់គាត់ ដែលនឹងស្រឡាញ់អ្នកដូចជាកូនៗពួកគេផ្ទាល់ ហើយដែលនឹងស្វែងរកការបំផុស គំនិត និងការដឹកនាំជំនួសអ្នក ។ ទ្រង់ជ្រាបពីដៃគូម្នាក់ៗរបស់អ្នក និងអ្វីដែលអ្នកនឹងរៀនពីពួកគេ ។ ទ្រង់ជ្រាបពីតំបន់នីមួយៗដែលអ្នកនឹងបម្រើ សមាជិកទាំងឡាយដែលអ្នកនឹងជួប មនុស្សដែលអ្នកនឹងបង្រៀន និងជីវិតដែលអ្នកនឹងជះឥទ្ធិពលលើគេរហូតដល់ភាពអស់កល្បជានិច្ច ។

តាមរយៈការបម្រើប្រកបដោយការពុះពារ និងការលះបង់ប្រកបដោយ  ឆន្ទៈ នោះបេសកកម្មរបស់អ្នកនឹងក្លាយទៅជាបទពិសោធន៍ដ៏បរិសុទ្ធចំពោះអ្នក ។ អ្នកនឹងធ្វើសាក្សីពីអព្ភូតហេតុនៃការផ្លាស់ប្រែចិត្តជឿខណៈដែលព្រះវិញ្ញាណធ្វើកិច្ចការ តាមរយៈអ្នកដើម្បីឲ្យដក់ជាប់នៅក្នុងដួងចិត្តអ្នកទាំងឡាយដែលអ្នកបង្រៀន ។

កាលណាអ្នករៀបចំដើម្បីបម្រើ នោះមាននូវអ្វីៗជាច្រើនដែលអ្នកត្រូវធ្វើ ។ ការក្លាយជាអ្នកបម្រើប្រកបដោយប្រសិទ្ធភាពរបស់ព្រះអម្ចាស់នឹងតម្រូវឲ្យមានលើសពីគ្រាន់តែការញែកចេញ ការពាក់ស្លាកឈ្មោះ ឬការចូលមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ។ វាគឺជាដំណើរការដែលចាប់ផ្ដើមយ៉ាងយូរពីមុនអ្នកត្រូវបានហៅថា « អែលឌើរ » ។

**មកកាន់បេសកកម្មរបស់អ្នកដោយមានទីបន្ទាល់ផ្ទាល់ខ្លួនអំពីព្រះគម្ពីរមរមន** ដែលទទួលបានតាមរយៈការសិក្សា និងការអធិស្ឋាន ។ ព្រះគម្ពីរមរមន គឺជាភស្ដុតាងដ៏មានឥទ្ធិពលអំពីទេវភាពនៃព្រះគ្រីស្ទ ។ ព្រះគម្ពីរជាភស្ដុតាងនៃការស្ដារឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធផងដែរ ។ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ អ្នកត្រូវតែមានទីបន្ទាល់ផ្ទាល់ខ្លួនជាមុនសិនថា ព្រះគម្ពីរមរមនពិត ។ សាក្សីពីព្រះវិញ្ញាណបរិសុទ្ធនេះ នឹងក្លាយទៅជាចំណុចគន្លឹះនៃការបង្រៀនរបស់អ្នក ។ ( See *Preach My Gospel: A Guide to Missionary Service* [ ឆ្នាំ 2004 ] ទំព័រ 105, 110 ) ។

**មកកាន់បេសកកម្មរបស់អ្នកដោយមានភាពសក្ដិសមនៃភាពជាដៃគូពីព្រះវិញ្ញាណបរិសុទ្ធ ។** នៅក្នុងប្រសាសន៍របស់ប្រធាន អែសរ៉ា ថាហ្វ បែនសឹនៈ « ព្រះវិញ្ញាណ គឺជាធាតុដ៏សំខាន់តែមួយគត់នៅក្នុងកិច្ចការនេះ ។ ជាមួយព្រះវិញ្ញាណតម្កើងមុខងាររបស់អ្នក នោះអ្នកអាចធ្វើអព្ភូតហេតុទាំងឡាយសម្រាប់ព្រះអម្ចាស់នៅក្នុងតំបន់បេសកកម្ម ។ បើគ្មានព្រះវិញ្ញាណ នោះអ្នកនឹងមិនទទួលបានជោគជ័យ សូម្បីតែទេពកោសល្យ និងសមត្ថភាពរបស់អ្នក » ( ប្រកាសដំណឹងល្អរបស់យើង ទំព័រ 180 ) ។

**មកកាន់បេសកកម្មរបស់អ្នកដោយត្រៀមខ្លួនរួចជាស្រេច ។** ជោគជ័យរបស់អ្នកក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ គឺត្រូវបានស្ទង់តាំងពីដំបូងតាមរយៈការតាំងចិត្តដើម្បីស្វែងរក បង្រៀន ធ្វើបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។ អ្នកនឹងរំពឹងឲ្យធ្វើការប្រកបដោយប្រសិទ្ធភាពជារៀងរាល់ថ្ងៃ ធ្វើអស់ពីសមត្ថភាពរបស់អ្នកដើម្បីនាំព្រលឹងមកឯព្រះគ្រីស្ទ ។ ( សូមមើល ប្រកាសដំណឹងល្អរបស់យើង ទំព័រ 10--11 ) ។

ខ្ញុំសុំរំឭកពីការអញ្ជើញរបស់ អែលឌើរ អិម រ័សុល បាឡឺដ បានផ្ដល់ឲ្យយុវជនមួយក្រុមមុនការរៀបចំដើម្បីបម្រើ ៖ «យើងសម្លឹងទៅអ្នក បងប្អូនប្រុសវ័យក្មេងនៃបព្វជិតភាពអើរ៉ុន ។ យើងត្រូវការអ្នក ។ ក៏ដូចជា កងទ័ពកម្លោះ 2,000នាក់របស់ហេលេមិន អ្នកជាបុត្រាខាងវិញ្ញាណរបស់ព្រះ ហើយអ្នកក៏អាចត្រូវបានភ្ជាប់ដោយសិទ្ធិអំណាចដើម្បីស្ថាបនា និងការពារនគររបស់ទ្រង់បានផងដែរ ។ យើងត្រូវការអ្នកឲ្យធ្វើនូវសេចក្ដីសញ្ញាដ៏ពិសិដ្ឋ ដូចដែល

ពួកគេបានធ្វើ ។ យើងត្រូវការអ្នកឲ្យគោរពប្រតិបត្តិដោយហ្មត់ចត់ និងស្មោះត្រង់ ដូចដែលពួកគេបានធ្វើ» («The Greatest Generation of Missionaries» *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2002 ទំព័រ 47) ។

នៅពេលអ្នកទទួលការអញ្ជើញនេះ នោះអ្នកនឹងរៀនមេរៀនដ៏មហិមាមួយ ដូចដែល អែលឌើរ ម៉ីស៊ីហ្គ្លូ និងអស់អ្នកទាំងឡាយដែលបានបម្រើ ត្រឡប់មកអនុវត្តដោយស្មោះត្រង់ ។ អ្នកនឹងរៀនថាពាក្យទាំងឡាយនៃដែលព្យាការីរបស់យើងប្រធាន ថូម៉ាស អេស ម៉នសុនបានមានប្រសាសន៍ ជាការពិត ។ « ឱកាសបេសកកម្មដែលមានតែម្តងក្នុងជីវិត គឺជារបស់អ្នក ។ ពរជ័យនៃភាពអស់កល្បជានិច្ច កំពុងរង់ចាំអ្នក ។ ឱកាសអ្នក គឺជាអភ័យឯកសិទ្ធិ ដើម្បីធ្វើជាអ្នកដែលពុំគ្រាន់តែសម្លឹងមើល ប៉ុន្តែធ្វើជាអ្នកចូលរួមនៅក្នុងឆាកនៃការបម្រើបព្វជិតភាពវិញ » (*Ensign* ខែ ឧសភា ឆ្នាំ 1995 ទំព័រ 49) ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការណ៍នេះពិត ។ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។